## សំនួរនិងចម្លើយ

**ស:** តើធ្វើយ៉ាងណាដើម្បីឲ្យដឹងថាកូនខ្ញុំអាចនឹងត្រូវនៅរៀនកំរិតថ្នាក់ដដែលមួយឆ្នាំទៀត?

**ច:** មាតាបិតាគប្បីអានរបាយការណ៏លិទ្ធផលសិក្សារបស់កូនគាត់ជានិច្ចដើម្បីតាមដានការលូតលាស់របស់កូន។ មាតាបិតានឹងត្រូវប្រាប់ឲ្យដឹងនៅក្នុងពេលជួបប្រជុំជាធម្មតានិងពេលជួបប្រជុំពិសេសហើយសំបុត្រនឹងផ្ញើទៅផ្ទះដើម្បីប្រាប់មាតាបិតាថាកូនគាត់រៀនមិនទាន់មានចំណេះស្មើនឹងកំរិតថ្នាក់ ឬអាចនឹងត្រូវនៅរៀនកំរិតថ្នាក់ដដែលមួយឆ្នាំទៀត។ សិស្សណាដែលអាចនឹងត្រូវនៅរៀនកំរិតថ្នាក់ដដែលនឹងបានទទួលការបង្ហាត់បង្រៀនជាបន្ថែមទៀតនៅសាលា។

**ស:** តើសាលារៀនមានផ្តល់អន្តរាគមន៏អ្វីខ្លះ?

**ច:** ពេលណាសិស្សរៀនមិនទាន់មានចំណេះស្មើនឹងកំរិតថ្នាក់យោងតាមការស្ទង់ប្រមាណមើលចំណេះអាននិងការគិតលេខ សិស្សនឹងអាចបានទទួលការបង្ហាត់បង្រៀនជាបន្ថែមនៅសាលា ដូចជាការបង្ហាត់បង្រៀនដ៏ប្រពលជាក្រុមសិស្សតិចគ្នាក្នុងការអាននិងការគិតលេខ ការបង្ហាត់បង្រៀនបន្ថែមក្រោយម៉ោងសាលា កម្មវិធីសិក្សានៅពេលវិស្សមកាល ឬថ្នាក់រៀនអក្សរសាស្រ្ត។ សាលាទាំងអស់នឹងផ្តល់ឱកាសដ៏ច្រើនបំផុតដល់សិស្សដើម្បីឲ្យរៀនបានជោគជ័យ។ មាតាបិតានឹងត្រូវរំពឹងថាផ្តល់ការគាំទ្រនៅផ្ទះហើយនឹងមានផ្តល់ឲ្យនូវការហ្វឹកហ្វឺនដើម្បីរៀនឲ្យចេះរបៀបជួយគាំទ្រកូនគាត់នៅផ្ទះ។

**ស:** តើខ្ញុំអាចជួយកូនខ្ញុំដោយរបៀបណានៅផ្ទះ?

**ច:** មាតាបិតាគប្បីទាក់ទងគ្រូបង្រៀនកូនគាត់ដើម្បីសុំរកជំនួយ។ សម្ភារៈសិក្សានិងសកម្មភាពសិក្សាផ្សេងៗ អាចនឹងត្រូវផ្តល់ឲ្យដើម្បីសម្រាប់ការហាត់អាន ហាត់សរសេរ និងហាត់ធ្វើលេខនៅផ្ទះ។ សាលារៀនតែងតែមានផ្តល់ការហ្វឹកហ្វឺនដល់មាតាបិតាហើយគាត់ក៏អាចចូលទៅវែបសាយរបស់ក្រសួងអប់រំបានដែរដើម្បីរកមើលការគាំទ្រផ្សេងៗ គឺនៅ www.lbschools.net. (ចុចលើពាក្យ “Parents” ហើយបន្ទាប់មកលើឃ្លា “Home Activities and Support”)

## សំនួរនិងចម្លើយ

**ស:** តើមានកម្មវិធីអន្តរាគមន៏អ្វីទៀតទេក្រៅពីកម្មវិធីរបស់ក្រសួងអប់រំ?

**ច:** មាតាបិតាអាចយកកូនទៅចុះឈ្មោះរៀនក្នុងកម្មវិធីសិក្សាក្នុងរដូវក្តៅឯកជនឬនៅតាមមជ្ឈមណ្ឌលបង្ហាត់បង្រៀនបន្ថែមផ្សេងៗនៅក្នុងសហគមន៏។ សិស្សនឹងបានទទួលនូវការស្ទង់មើលចំណេះនៅសាលាហើយមាតាបិតាអាចយកលិទ្ធផលនៃការស្ទង់ចំណេះនេះទៅមជ្ឈមណ្ឌលដើម្បីឲ្យគេគិតគូរកមើលសេចក្តីចាំបាច់របស់សិស្ស។

**ស:** បើសិនជាសិស្សណាម្នាក់ធ្វើមិនជាប់តែសផ្នែកគិតលេខ តើសិស្សនោះអាចនឹងត្រូវនៅរៀនកំរិតថ្នាក់ដដែលដែរឬទេ?

**ច:** អញ្ចឹងមែន។ សិស្សពីថ្នាក់ទី១ដល់ទី៥នឹងបានទទួលឱកាសដ៏ច្រើនជាទីបំផុតដើម្បីធ្វើតែសគិតលេខឲ្យជាប់នៅក្រោមស្ថានភាពធ្វើតែសជាធម្មតា។ បើសិស្សនៅក្នុងកម្មវិធីអប់រំពិសេសសិស្សនោះនឹងបានទទួលការសម្របសម្រួលតម្រូវទៅតាមសមត្ថភាព ដូចមានសរសេរនៅក្នុងផែនការអប់រំផ្ទាល់ខ្លួនពិសេសរបស់សិស្ស (IEP) ។

**ស:** តើខ្ញុំជាមាតាបិតាមានសិទ្ធិបដិសេធទៅលើការដាក់ឲ្យកូនខ្ញុំនៅរៀនកំរិតថ្នាក់ដដែលនេះទេ?

ពេលណាសិស្សបានទទួលអនុសាសន៏ឲ្យនៅរៀនកំរិតថ្នាក់ដដែលក្រុមពិនិត្យមើលស្តង់ដាសម្រាប់ឲ្យសិស្សឡើងថ្នាក់មួយនៅសាលានឹងជួបប្រជុំដើម្បីពិនិត្យមើលលក្ខណះវិនិច្ឆ័យ ប្រវត្តសិក្សាហើយនិងលិទ្ធផលសិក្សាជាមួយមាតាបិតា។ ក្រុមនេះគឺមានរួមទាំងមាតាបិតា នឹងធ្វើការសម្រេចជាលើកចុងក្រោយ។ បើសិនជាមាតាបិតាមិនយល់ស្របជាមួយការសម្រេចរបស់ក្រុមទេ គាត់អាចដាក់ពាក្យស្នើសុំឲ្យមានការវិនិច្ឆ័យឡើងវិញជាមួយសាលារៀននោះ។

ដើម្បីឲ្យដឹងថែមអំពីបទបញ្ញាស្តីអំពីការឲ្យឡើងថ្នាក់និងការឲ្យនៅរៀនកំរិតថ្នាក់ដដែល សូមចូលទៅវែបសាយ www.lbschools.net ហើយចុច “Retention” ពីបញ្ជីលេខរៀងតួរអក្សរ។

# បទបញ្ញាស្តីពីការឱ្យឡើងថ្នាក់ និងការឱ្យនៅរៀនកំរិតថ្នាក់ ដដែលសំរាប់សិស្សបឋមសិក្សា



## មគ្គុទ្ទេសក៏សំរាប់មាតាបិតា

ខែកញ្ញា ឆ្នាំ ២០០៩

# បទបញ្ញាស្តីពីការឱ្យឡើងថ្នាក់និងការឱ្យនៅរៀនកំរិតថ្នាក់ដដែលសម្រាប់សិស្សបឋមសិក្សា

## សាវតា

កាលពីឆ្នាំ១៩៩៦ ក្រុមប្រឹក្សាភិបាលក្រសួងអប់រំបានធ្វើការយល់ព្រមលើកទីដំបូងនូវច្បាប់កែធ្វើឲ្យប្រសើរឡើងនូវការសិក្សាដែលទាក់ទងនឹងការឲ្យឡើងថ្នាក់និងការឲ្យនៅរៀនថ្នាក់កំរិតដដែល។ តាំងពីពេលនោះមក បទបញ្ញាមួយចំនួនសម្រាប់ថ្នាក់ទី១ដល់ទី៥បានក្លាយជាចំណែកមួយនៃផែនការចំបងរបស់ក្រសួងអំរំក្នុងការបង្កើនសមិទ្ធិផលរបស់សិស្សដោយតំរូវឲ្យសិស្សរៀនឲ្យស្របបានដូចលក្ខណៈវិនិច្ឆ័យផ្សេងៗក្នុងការអាននិងការសរសេរ។

## គោលបំណង

វិធានការណ៏មួយឆ្ពោះទៅកាន់ការបញ្ឈប់នូវការឲ្យសិស្សឡើងដោយពុំមានចំណេះវិជ្ជាគ្រប់គ្រាន់ត្រូវបានប្រតិបត្តិឡើងនៅពេលក្រសួងអប់រំឡុងប៊ីចបានធ្វើការយល់ព្រមទៅលើបទបញ្ញាស្តីពីការឲ្យឡើងថ្នាក់និងការឲ្យនៅរៀនកំរិតថ្នាក់ដដែល។ បទបញ្ញានៃការឲ្យឡើងថ្នាក់និងការឲ្យនៅរៀនកំរិតថ្នាក់ដដែលនេះគឺដើម្បីធ្វើឲ្យប្រាកដថា សិស្សទាំងអស់មាននូវជំនាញការចេះដឹងសំខាន់ៗដល់កំរិតខ្ពស់ក្នុងសមិទ្ធិផលនៃការសិក្សា។ គ្រប់កំរិតថ្នាក់ពីថ្នាក់ទី១ដល់ទី៥ លក្ខណៈវិនិច្ឆ័យមួយក្នុងការឲ្យសិស្សឡើងថ្នាក់ត្រូវបានបង្កើតឡើង ដែលតំរូវឲ្យសិស្សរៀនឲ្យបានចំណេះកំរិតគ្រប់គ្រាន់ល្មម មុននឹងអាចឡើងទៅថ្នាក់កំរិតបន្ទាប់ទៀត។

## គោលដៅ

ក្រុមប្រឹក្សាភិបាលសង្ឃឹមថាសិស្សនឹងមានការលូតលាស់នៅក្នុងកំរិតថ្នាក់នីមួយៗក្នុងកំឡុងពេល១ឆ្នាំសិក្សា។ ដើម្បីធ្វើឲ្យបានសម្រេចយ៉ាងនេះ ការបង្ហាត់បង្រៀនត្រូវតែតម្រូវទៅតាមរបៀបផ្សេងៗនៃការរៀនសូត្រជាច្រើនយ៉ាងដើម្បីឲ្យសិស្សរៀនឆាប់ចេះហើយនិងមានរួមបញ្ចូលនូវយុទ្ធសាស្ត្រផ្សេងៗដើម្បីបំពេញដល់សេចក្តីខ្វះខាតក្នុងចំណេះវិជ្ជានៅពេលណាដែលចាំបាច់។

1515 Hughes Way
Long Beach, California 90810
www.lbschools.net

### ការឲ្យនៅរៀនថ្នាក់ដដែលក្នុងថ្នាក់ទី១

សិស្សថ្នាក់ទី១ដែលមិនទាន់មានចំណេះគ្រប់គ្រាន់ស្មើពាក់កណ្តាលកំរិតថ្នាក់ទី១ក្នុងផ្នែកអានហើយនិងផ្នែកបូកលេខនិងដកលេខដែលមានចំនួនសរុបដល់១០នឹងត្រូវទទួលការពិចារណាសម្រាប់ឲ្យនៅរៀនថ្នាក់ទី១មួយឆ្នាំទៀត។

### ការឲ្យនៅរៀនថ្នាក់ដដែលក្នុងថ្នាក់ទី២

សិស្សថ្នាក់ទី២ដែលមិនទាន់មានចំណេះគ្រប់គ្រាន់ស្មើចុងកំរិតថ្នាក់ទី១ក្នុងផ្នែកអានហើយនិងធ្វើមិនជាប់តែសលេខបូកនិងលេខដកស្មើនឹងកំរិតថ្នាក់នៅចុងឆ្នាំទេនោះនឹងត្រូវទទួលការពិចារណាសំរាប់ឲ្យនៅរៀនថ្នាក់ទី២មួយឆ្នាំទៀត។

### ការឲ្យនៅរៀនថ្នាក់ដដែលក្នុងថ្នាក់ទី៣

សិស្សថ្នាក់ទី៣ដែលមិនទាន់មានចំណេះគ្រប់គ្រាន់ស្មើចុងកំរិតថ្នាក់ទី២ក្នុងផ្នែកអាននៅចុងឆ្នាំហើយនិងមិនទាន់មានចំណេះគ្រប់គ្រាន់ក្នុងការធ្វើលេខបូកនិងលេខដកហើយនិងមានចំណេះខ្វះៗល្មមផ្នែកលេខគុណនិងលេខចែកនៅចុងឆ្នាំទេនោះនឹងត្រូវទទួលការពិចារណាសម្រាប់ឲ្យនៅរៀនថ្នាក់ទី៣មួយឆ្នាំទៀត។

### ការឲ្យនៅរៀនថ្នាក់ដដែលក្នុងថ្នាក់ទី៤

សិស្សថ្នាក់ទី៤ដែលមិនទាន់មានចំណេះគ្រប់គ្រាន់ស្មើចុងកំរិតថ្នាក់ទី៣ក្នុងផ្នែកអាននិងធ្វើមិនជាប់នូវតែសគិតលេខទាំងបួនមុខឲ្យបានស្មើកំរិតថ្នាក់ទេនៅចុងឆ្នាំសិក្សានឹងត្រូវទទួលការពិចារណាសំរាប់ឲ្យនៅរៀនថ្នាក់ទី៤មួយឆ្នាំទៀត។

### ការឲ្យនៅរៀនថ្នាក់ដដែលក្នុងថ្នាក់ទី៥

សិស្សថ្នាក់ទី៥ដែលមិនទាន់មានចំណេះគ្រប់គ្រាន់ស្មើចុងកំរិតថ្នាក់ទី៤ក្នុងផ្នែកអាននិងធ្វើមិនជាប់នូវតែសគិតលេខទាំងបួនមុខឲ្យបានស្មើកំរិតថ្នាក់ទេនៅចុងឆ្នាំសិក្សានឹងត្រូវទទួលការពិចារណាសំរាប់ឲ្យនៅរៀនថ្នាក់ទី៥មួយឆ្នាំទៀត។

## ដំណើរការនៃការឲ្យឡើងថ្នាក់និងការឲ្យនៅថ្នាក់កំរិតដដែល

**ទំនាក់ទំនងនិងការជូនដំណឹង**
- ការជួបប្រជុំនឹងមាតាបិតានៅរដូវឈើជ្រុះស្លឹកនិងរដូវផ្ការីក។
- សំបុត្រជូនដំណឹងនៅក្នុងរដូវផ្ការីក។

**អន្តរាគមន៏ផ្សេងៗ**
- ការគាំទ្រក្នុងថ្នាក់រៀននៅសាលា។
- ការបំប៉នពង្រឹងជំនាញនៅផ្ទះ។

**ការជួបប្រជុំក្រុមពិនិត្យមើលស្តង់ដាសំរាប់ឲ្យឡើងថ្នាក់**
- គ្រូបង្រៀន អ្នកផ្តល់ឱវាទ អភិបាលសាលា និង មាតាបិតា។

**ការពិនិត្យពិចារណាមើលសម្រាប់ការដាក់ឲ្យនៅរៀនថ្នាក់កំរិតដដែល។**
មាតាបិតាអាចដាក់ពាក្យសុំឲ្យធ្វើការពិនិត្យវិនិច្ឆ័យឡើងវិញ

**ការពិនិត្យមើលសាឡើងវិញហើយនិងការសម្រេចជាលើកចុងក្រោយ។**